ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ៧៣៤/១៩ គ.ជ.ប.ជ

# របាយការណ៍ខែកញ្ញា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែតុលា ឆ្នាំ២០១៩

## I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីរាជរដ្ឋាភិបាលថៃ បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល ពលរដ្ឋខ្មែរនៅតែបាន និងកំពុងចូលទៅធ្វើការនៅប្រទេសថៃ ដោយខុសច្បាប់ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានីភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌ ពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលា ជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ច ផ្តល់ឯកសារក្លែងក្លាយជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព ដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
  - ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្ដីពី "ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្ដីពី "ការបញ្ជូនទណ្ឌិត"។

ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
  - អនុស្សរណៈនៃការយោគយល់គ្នា រវាងក្រសួងមហាផ្ទៃ និងសកម្មភាពដើម្បីកុមារ (APLE Cambodia) ស្ដីពីការចូលរួមចំណែកលើសកម្មភាពមនុស្សធម៌ ក្នុងកិច្ចការពារកុមារនៅប្រទេសកម្ពុជា នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩។
  - អនុស្សរណៈនៃការយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩។
- ក្រសួងអប់រំ យុវជន និងកីឡា៖ កំពុងធ្វើសេចក្ដីព្រាងគោលនយោបាយ ស្ដីពី "កិច្ចការការពារកុមារតាមសាលារៀន"។
- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្ដីពី "ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី"។

ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ៖ ធ្វើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត "សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្ដីព្រាងរៀបចំអនុក្រឹត្យ ស្ដីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

# ខ. ការបង្ការ ទប់ស្កាត់

## ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

### ខ.១.១. ការផ្សព្វផ្សាយដោយផ្ទាល់

នៅក្នុងខែកញ្ញា ឆ្នាំ២០១៩នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ៨.៣៩៣លើក មានអ្នកចូលរួមសរុបចំនួន ៤២៦.៤១១នាក់ (ធៀបនឹងខែសីហា មានចំនួន ៤០៦.៣៩៦នាក់ គឺមានការកើនឡើងចំនួន ២០.០១៥នាក់ ស្មើនឹង៤,៩២% ក្នុងនោះស្ត្រីចំនួន ២៣១.៥០៦នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

# តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| **ក្រសួង ស្ថាប័ន** | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១២០ | ៨.១៤៥ | ៤.៩១២ | | | |
| | សរុប ក្រសួង ស្ថាប័ន | ១២៨ លើក | ៨.៩៥៩ នាក់ | ៦.៦៦៧ នាក់ | | | |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ២៩៨ | ១០.១៣២ | ៥.៩៣០ | ៨៤២ | ៣៨.២៧៥ | ២០.០៧៦ |
| ៣ | ខេត្តបាត់ដំបង | ១.១៣៤ | ៤៥.៧៣៩ | ២៨.២០១ | ៧០២ | ២៤.៦៨៤ | ១២.៦៨១ |
| ៤ | ខេត្តពោធិ៍សាត់ | ៦៣២ | ៧៤.០១៤ | ៣៩.៥៣៨ | ២១១ | ៦.២៦៣ | ៣.៣១៨ |
| ៥ | ខេត្តសៀមរាប | ៤៦៣ | ២៩.៨៧៦ | ១៧.៤៩៣ | ៤២ | ១.៥៩១ | ១.១៨៦ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.១៣៧ | ៥៦.៣១១ | ២៧.៨៩០ | ៦៣៤ | ២៥.០៧៧ | ១៣.២៤៥ |
| ៧ | ខេត្តកំពង់ចាម | ៨៣៧ | ៣៩.៦០០ | ២០.៩៦៨ | ២៥៨ | ៨.១៩៤ | ៥.៤៥១ |
| ៨ | ខេត្តព្រះសីហនុ | ១៩ | ១.៦៦២ | ៧០៣ | ១ | ១០២ | ២៣ |
| ៩ | ខេត្តព្រះវិហារ | | | | | | |
| ១០ | ខេត្តស្វាយរៀង | ១២ | ៥៧៩ | ៣៧៨ | ៣១៨ | ១២.១៣៨ | ៦.៣៤៤ |
| ១១ | ខេត្តប៉ៃលិន | ៨៧ | ៤.២១៧ | ១.៩៤៦ | ៤១ | ៣.៦៤៧ | ១.៦៦៨ |
| ១២ | ខេត្តកោះកុង | ៣ | ៨៤ | ៦៣ | ៥១ | ១.៨៨៤ | ៩៧៤ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | ១ | ៩១ | ៣៣ | | | |
| ១៥ | ខេត្តតាកែវ | ២៥១ | ១០.៦៥៤ | ៤.៨៣៥ | ១៥២ | ៥.៤៣០ | ២.៣៨១ |
| ១៦ | ខេត្តក្រចេះ | ១ | ៧៦ | ៤៨ | | | |
| ១៧ | ខេត្តកែប | ២៣ | ៧.៣៧១ | ៤.២០៨ | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | ៥១ | ១.៧០១ | ៧៦២ | ៥៥ | ៤.៤៤៥ | ២.២៣០ |
| ២១ | ខេត្តព្រៃវែង | ១ | ១.៥៤៧ | ១.០៦៦ | | | |
| ២២ | ខេត្តត្បូងឃ្មុំ | | | | ៣ | ២៧៩ | ២០៣ |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | ៥ | ១.៧៨៩ | ៩៩៧ |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ៤.៩៥០ លើក | ២៨៣.៦៥៤ នាក់ | ១៥៤.០៦២ នាក់ | ៣.៣១៥ លើក | ១៣៣.៧៩៨ នាក់ | ៧០.៧៧៧ នាក់ |

| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន ៨.៣៩៣ លើក | អ្នកចូលរួមសរុបចំនួន ៤២៦.៤១១ នាក់ | ស្ត្រីចំនួន ២៣១.៥០៦ នាក់ |
|---|---|---|---|

### ខ.១.២. ការផលិតឧបករណ៍ផ្សព្វផ្សាយ (IEC)

- ខេត្តស្វាយរៀង៖

លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការ ឆាលហ្វាន និងCCPCR ធ្វើការតំឡើងផ្ទាំងប៉ាន់ណូថ្មី ស្តីពីការអប់រំក្នុងការធ្វើចំណាកស្រុក និងការជួញដូរមនុស្ស ចំនួន ០៦ផ្ទាំង និងប្តូរប៉ាន់ណូចាស់ ចំនួន ១៣ផ្ទាំង។

### ខ.១.៣. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក

- ខេត្តសៀមរាប៖

មន្ទីរព័ត៌មានខេត្ត បានសហការជាមួយអង្គភាព អាផ្វាធរ និងអង្គការពាក់ព័ន្ធ ធ្វើកម្មវិធី "យើងធ្វើបាន" និង "សន្ទនាមតិ" បានសរុបចំនួន ៣៦លើក (ផ្សាយផ្ទាល់ ១០លើក ចាក់ផ្សាយឡើងវិញ ២៦លើក)។

- ខេត្តតាកែវ៖
- ផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុ បាន ចំនួន ០៥អត្ថបទ និង ៤៥លើក។

### ខ.១.៤. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

- ថ្នាក់ក្រោមជាតិ
- ខេត្តកំពង់ចាម៖

បានចូលរួមជាវាគ្មិននៅស្ថានីយ៍វិទ្យុជាតិភ្នំស្រីភ្នំប្រុស លើប្រធានបទស្តីពី ការស្វែងរកការងារ ធ្វើក្នុងស្រុក និងការទប់ស្កាត់ចំណាកស្រុកមិនស្របច្បាប់ ចំនួន ០១លើក។

## ខ.២. ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ

### ខ.២.១. វិធានការជំនាញអន្តោប្រវេសន៍៖ ការគ្រប់គ្រងជនបរទេស

១. <u>ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់:</u> ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា សរុបចំនួន ៣០លើក មនុស្សចំនួន ២០៥នាក់(ស្រី ២១នាក់) មាន ០៩សញ្ជាតិ។

២. <u>ការបដិសេធមិនឲ្យចូលប្រទេស:</u> ការពង្រឹង បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស លើជនបរទេស ចូល-ចេញតាមបណ្តាច្រកទ្វារព្រំដែនអន្តរជាតិនានា ក្នុងខែនេះបានធ្វើការបដិសេធមិនឲ្យចូលប្រទេសមានចំនួន ៦៣លើក មនុស្សចំនួន ១១០នាក់ លើ ១៣៩នាក់ (ថយចុះ ២០,៨៦%) ក្នុងនោះមាន៖

- គោលបំណងនៃការធ្វើដំណើរមិនច្បាស់លាស់ គ្មានប្រាក់គ្រប់គ្រាន់ក្នុងការស្នាក់នៅព្រះរាជាណាចក្រកម្ពុជាចំនួន ៤៦លើក មនុស្សចំនួន ៨៧នាក់ មាន ២១សញ្ជាតិ។
- បទល្មើសផ្សេងៗចំនួន ១៩លើក មនុស្សចំនួន ២៣នាក់ មាន ០៧សញ្ជាតិ។

### ខ.២.២. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- អគ្គស្នងការដ្ឋាននគរបាលជាតិ

ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែចំពោះពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន ៣៤៥.២៨៤នាក់/៣៦១.៧១៥នាក់ (ស្រី ១៣៧.០៤៩នាក់)

អនីតិជន ៦.៣៣៤នាក់ (ស្រី ២.៤៧២នាក់) ក្នុងនោះស្របច្បាប់ចំនួន ២១៧.៩១២នាក់/ ២២១.៩១៩នាក់ (ស្រី ៨២.៧៣៣នាក់) អនីតិជន ៦៥៤នាក់ (ស្រី ២៧៨នាក់) មិនស្របច្បាប់ ចំនួន ១២៧.៣៧២នាក់/១៣៩.៧៩៦នាក់ (ស្រី ៥៤.៣១៦នាក់) អនីតិជន ៥.៦៨០នាក់ (ស្រី ២.១៩៤នាក់) បើប្រៀបធៀបនឹងខែសីហា គឺមានការថយចុះចំនួន ១.៦៤៣នាក់ ស្មើនឹង ៤,៥៤%។

- **ខេត្តសៀមរាប៖** កងរាជអាវុធហត្ថខេត្ត បានអញ្ជើញម្ចាស់ទីតាំងខារ៉ាអូខេ ម៉ាស្សា និងភោជនីយដ្ឋាន មកធ្វើការណែនាំ និងធ្វើកិច្ចសន្យា ដើម្បីបង្ការទប់ស្កាត់បទល្មើសផ្សេងៗ ចំនួន ០៤លើក។
- **ខេត្តតាកែវ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាម បណ្តារោងចក្រ សហគ្រាស ដើម្បីត្រួតពិនិត្យមើលលក្ខខ័ណ្ឌការងារ ការអនុវត្តច្បាប់ស្តីពីការងារ និងផ្សព្វផ្សាយច្បាប់ស្តីពីការធ្វើចំណាកស្រុក និងផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយខុសច្បាប់ សរុបចំនួន ០៦លើក ។
- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈសេនាតូច ការពារព្រំដែនគោកលេខ ៨១៧ ៨១៩ ៨២៣ និង ៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនដើម្បី ទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ចំនួន ៦៥លើក ពុំប្រទះឃើញពលករឆ្លងដែនខុសច្បាប់ទេ។
- **ស្នងការដ្ឋាននគរបាលខេត្តរតនគិរី៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈនគរបាលការពារ ព្រំដែនគោក បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួន ចំនួន ៦៨លើក (ព្រំដែន កម្ពុជា-វៀតណាម ៥៤លើក និងព្រំដែនកម្ពុជា-ឡាវ ១៤លើក)ដើម្បីទប់ស្កាត់បទល្មើសឆ្លងដែន ខុសច្បាប់។

**ខ.២.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្ត បទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ សរុបចំនួន **៧៥គោលដៅ** ក្នុងនោះអំពើជួញដូរ មនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន **៦៦គោលដៅ**។
  - ស្នងការដ្ឋាននគរបាលខេត្តតាកែវ មណ្ឌលគិរី កែប ស្វាយរៀង ក្រចេះ ឧត្តរមានជ័យនិងខេត្ត កោះកុង បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើស សញ្ចារកម្ម និងផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ ម្ចាស់អាជីវកម្មស្ត្រីក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន **៤៨៧គោលដៅ** មានមនុស្សចំនួន **៧.២៥០នាក់** (ស្រី **៤.៧១២នាក់**)។
  - ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង កំពង់ស្ពឺ តាកែវ ព្រៃវែង ក្រចេះ និងខេត្តព្រះវិហារ ល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ៣៤លើក។

**ខ.២.៤. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) នៃច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារ

អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ១៨៤គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស តាមរយៈទូរស័ព្ទផ្ទាល់ ចំនួន ១៩នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍។

**ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- ខេត្តសៀមរាប៖

  មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះផ្សព្វផ្សាយផលប៉ះពាល់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ បានចំនួន ៣៨លើក។

- ខេត្តកំពង់ឆ្នាំង៖

  ស្នងការដ្ឋាននគរបាលខេត្ត បានចុះត្រួតពិនិត្យសិប្បកម្មឡឥដ្ឋចំនួន ១៥កន្លែង មានកម្មករសរុប ២៩៣នាក់ (ស្រី ១២២នាក់) ដោយពុំមានឃើញកម្មករជាអនីតិជនឡើយ។

- ខេត្តរតនគិរី៖

  មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចសាមញ្ញចំនួន ២០លើក និងអធិការកិច្ចពិសេសចំនួន ០៥លើក ក្នុងគោលបំណងពិនិត្យលើការងារអនុវត្តច្បាប់ ស្តីពីការងារបង្ការការប្រើប្រាស់កំលាំងពលកម្មខុសច្បាប់ និងការប្រើប្រាស់ពលកម្មកុមារ។

- ខេត្តប៉ៃលិន៖

  បានចុះធ្វើអធិការកិច្ច ដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់កម្លាំងពលកម្មដូចជា សែឡូ កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន ចំនួន ៨០កន្លែង។

- ខេត្តក្រចេះ៖

  មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចុះត្រួតពិនិត្យមណ្ឌល អង្គការដំណឹងល្អចំនួន ០៤ ។

- ខេត្តព្រះសីហនុ៖

  **ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ** សហការជាមួយអង្គការម្លប់តាប៉ាង ដើម្បីការពារសុវត្ថិភាពកុមារ បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្របណ្តាញតាមសហគមន៍ និងផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន ១.១៣៣នាក់។

**ខ.៤. ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការផ្តល់ប័ណ្ណព្រំដែនដល់មុខសញ្ញាងាយរងគ្រោះ**

- រដ្ឋបាលខេត្តចំនួន០២ គឺខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន **៥.២៧៧**ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មាន៖
  - ខេត្តបាត់ដំបង ចំនួន ៤.១២២ប័ណ្ណ
  - ខេត្តប៉ៃលិន ចំនួន ១.១៥៥ប័ណ្ណ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តៈ រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ កំពង់ស្ពឺ កំពត ក្រចេះ ព្រះវិហារ ព្រៃវែង ព្រះសីហនុ និងខេត្តតាកែវ។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៥ករណី (ធៀបនឹងខែសីហា មានចំនួន ០៩ករណី កើនឡើង ០៦ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ២៦នាក់ (ស្រី ០៦នាក់) ក្នុងនោះជនសង្ស័យជាអនីតិជនចំនួន ០២នាក់ និងជនបរទេស ១២នាក់ សញ្ជាតិចិន ១០នាក់ អង់គ្លេស ០១នាក់ និងអូស្ត្រាលី ០១នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ៥៦នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១០នាក់ អាយុ១៥-១៧ឆ្នាំ ០៧នាក់ និងអាយុពី១៨ឆ្នាំឡើង ៣៩នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ២៨នាក់ និងប្រគល់ឲ្យគ្រួសារ ២៨នាក់) ក្នុងនោះមានបែកជាៈ

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០២ករណី លើ០៤ករណី (ថយចុះ ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ (អនីតិជន ០១នាក់) សង្គ្រោះជនរងគ្រោះចំនួន ០៣នាក់ អាយុពី១៨ឆ្នាំឡើង ០៣នាក់ (ប្រគល់ឲ្យគ្រួសារ)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០២ | ០៣ | ០២ |
| *សរុប* | *០២ ករណី* | *០៣ នាក់* | *០២ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១៣ករណី លើ០៥ករណី (កើនឡើង ០៨ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ២៤នាក់ (ស្រី ០៦នាក់ អនីតិជន ០១នាក់ ជនជាតិចិន ១២នាក់)។

សង្គ្រោះជនរងគ្រោះចំនួន ៥៣នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១០នាក់ អាយុ១៥-១៧ឆ្នាំ ០៧នាក់ និងអាយុពី១៨ឆ្នាំឡើង ៣៦នាក់ (ប្រគល់ទៅមន្ទីរសង្គមកិច្ច ២៨នាក់ និងប្រគល់ឲ្យគ្រួសារ ២៥នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -សញ្ចារកម្ម | ០២ | ១៣ | ១០ | ចិន១០ |
| -សញ្ចារកម្ម(មានអនីតិជន) | ០១ | ២១ | ០៣ | |
| -សញ្ចារកម្ម( ទាក់ទងនឹងពេស្យាចារកុមារ) | ០១ | ០៧ | ០២ | អង់គ្លេស១ អូស្ត្រាលី១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៩ | ០៦ | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | ០៣ | |
| *សរុប* | *១៣ ករណី* | *៥៣ នាក់* | *២៤ នាក់* | *១២ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ សរុបចំនួន ៤.០៣៩នាក់ (ស្រី ១.៨៣៧នាក់)ក្នុងនោះមាន៖

| ល.រ | ឈ្មោះប្រទេសគោលដៅ | មូលហេតុនៃការវិលត្រឡប់ | សរុប | ស្រី | ប្រុស | កុមារ |
|---|---|---|---|---|---|---|
| ១ | ថៃ | ពលករខុសច្បាប់ | ៤.០២១ | ១.៨២០ | ៤.០២០ | ៨១ |
| ២ | ចិន | សង្ស័យជួញដូរ | ១១ | ១១ | | |
| ៣ | ម៉ាឡេស៊ី | ពលករខុសច្បាប់ | ០៥ | ០៤ | ០១ | |
| ៤ | វៀតណាម | សង្ស័យជួញដូរ | ០២ | ០២ | | |
| សរុបរួម | | | ៤.០៣៩នាក់ | ១.៨៣៧នាក់ | ៤.០២១នាក់ | ៨១នាក់ |

- អគ្គស្នងការដ្ឋាននគរបាលជាតិ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសពលករខ្មែររងគ្រោះចំនួន ២៨នាក់(ស្រី ២១នាក់) ដែលត្រឡប់ពីប្រទេសចិន ១៩នាក់ ម៉ាឡេស៊ី ០៨នាក់ និងប្រទេសអារ៉ាប់ប៊ីសាអូឌីត ០១នាក់។ តាមការសម្ភាសបានឲ្យដឹងថាទៅតាមរយៈមេខ្យល់ ២៥នាក់ ទៅដោយខ្លួនឯង ០១នាក់ និងទៅតាមក្រុមហ៊ុន ០២នាក់។

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍

បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ៩២លើក មនុស្សចំនួន ១.០៥១នាក់(ស្រី ៣៤៩នាក់ កុមារ ១០៦នាក់)។ ក្នុងនោះតាម៖

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ១៥លើក មនុស្សចំនួន ៤៩នាក់ (ស្រី ៣២នាក់)
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ៧៧លើក មនុស្សចំនួន ១.០០២នាក់ (ស្រី ៣១៧នាក់)
  កុមារចំនួន ១០៦នាក់។

- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

ស្នងការដ្ឋាននគរបាលខេត្ត ចំនួន៣ បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន ៦២លើក មនុស្សចំនួន ៩២២នាក់(ស្រី ៣០៧នាក់ អនីតិជន ១០៩នាក់) ក្នុងនោះមាន៖

- ខេត្តបន្ទាយមានជ័យ ចំនួន ៤៧លើក មនុស្សចំនួន ៨៥៦នាក់ (ស្រី ២៨២នាក់)
  អនីតិជនចំនួន ១០៦នាក់។
- ខេត្តបាត់ដំបង ចំនួន ១១លើក មនុស្សចំនួន ៦០នាក់ (ស្រី ២១នាក់)
  អនីតិជនចំនួន ០៣នាក់។
- ខេត្តកោះកុង ចំនួន ០៤លើក មនុស្សចំនួន ០៦នាក់ (ស្រី ០៤នាក់)។

*ក្នុងនោះមានពលរដ្ឋចំនួន ៨៥នាក់ (ស្រី ៣៤នាក់ អនីតិជន ១៧នាក់) ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែ មុននឹងបញ្ជូនមកកម្ពុជាវិញ។ Sotha

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការងារបណ្តុះបណ្តាល

#### ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានសហការជាមួយអង្គការ IOM បើកកម្មវិធីវគ្គបណ្តុះបណ្តាល ស្តីពីការប្រមូល និងវិភាគទិន្នន័យដើម្បីគាំទ្រដល់ការតស៊ូមតិ និងផ្តល់សេវាផ្អែកលើកស្តុតាងសម្រាប់ជនទេសន្តប្រវេសន៍ដែលងាយរងគ្រោះ នៅសណ្ឋាគារសោម៉ាទេវីរីស៊ត។ | ០១ | ៣៥ | ១១ |
| ២ | **ខេត្តស្វាយរៀង** បើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវច្បាប់លើស្ត្រី និងកុមារ។ | ០១ | ៤៥ | ៤១ |
| ៣ | **ខេត្តតាកែវ** បើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវច្បាប់លើស្ត្រី និងកុមារ។ | ០១ | ៤៥ | ៤១ |
| ៤ | **ខេត្តកំពង់ឆ្នាំង** បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីសកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា។ | ០១ | ៤២ | ៣៨ |
| ៥ | **ខេត្តព្រះវិហារ** ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាលហ្វឹកហ្វឺនលើកទី២ ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ ក្នុងការសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះ ដល់មន្ត្រី មកពីស្នងការដ្ឋាន-អធិការដ្ឋាន-ប៉ុស្តិ៍នគរបាល មន្ទីរសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា និងមន្ទីរកិច្ចការនារី។ | ០១ | ៣០ | ០៦ |
| ៦ | **ខេត្តសៀមរាប៖**<br>-លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការ APLE បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់ និងការឆ្លើយតបចំពោះសញ្ញាណរងគ្រោះនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅស្រុកប្រាសាទបាគង អ្នកចូលរួម ៤០នាក់ ស្រី ២០នាក់។<br>-អង្គការ We World / GVC សហការជាមួយអាជ្ញាធរស្រុកពួក បើកវគ្គបណ្តុះ បណ្តាលពង្រឹងសមត្ថភាពដល់ជនបង្គោល ស្តីពីសិទ្ធិការងារ និងការទប់ស្កាត់ពីការបោកបញ្ឆោតក្នុងគោលបំណងកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរមនុស្សគ្រប់ទម្រង់ អ្នកចូលរួម ១៩នាក់ ស្រី ១១នាក់។ | ០២ | ៥៩ | ៣១ |
| | សរុប | **០៧ វគ្គ** | **២៥៦ នាក់** | **១៦៨ នាក់** |

#### ក.១.២.ការបណ្តុះបណ្តាលក្រៅប្រទេស

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចាត់បញ្ជូននាយនគរបាលចំនួន ០៣រូប ដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការបង្ក្រាបបទល្មើសលើកុមារតាមប្រព័ន្ធអ៊ីនធឺណែត នៅប្រទេសម៉ាឡេស៊ី។

### ក.២. សិក្ខាសាលា

#### ក.២.១.សិក្ខាសាលាក្នុងប្រទេស

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានរៀបចំកម្មវិធីដាក់បង្ហាញលើដំណើរការសាកល្បងគេហទំព័រ និងកម្មវិធីស្មាតហ្វូន "NCCT PARTNER RESOURCES AND SERVICE REFERRALS" ក្រោម

អធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ ដែលមានអ្នកចូលរួមចំនួន ៧០នាក់ (ស្រី ៣១នាក់) ជាតំណាងមកពី គ.រ.ប.ជ/គ.ខ.ប.ជ ទាំង២៥ រាជធានី-ខេត្ត ក្រសួង ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ។

#### ក.២.២.សិក្ខាសាលាក្រៅប្រទេស

- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចាត់ថ្នាក់ដឹកនាំក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ចំនួន ០២រូប ដើម្បីទៅចូលរួមក្នុងវេទិកាស្ត្រី ដែលមានអ្នកចូលរួមប្រមាណ ១.២០០នាក់ មកពី៥០ ប្រទេស នៅប្រទេសសឹង្ហបុរី។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១ សន្និសីទ

- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចាត់ថ្នាក់ដឹកនាំក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ចំនួន ០២រូប ដើម្បីទៅចូលរួមកិច្ចប្រជុំពេញអង្គសន្និសីទថ្នាក់តំបន់អាស៊ីអាគ្នេយ៍ សម្រាប់វិស័យនេសាទ ដែលរៀបចំដោយអង្គការ ILO និង Ministry of Maritime Affairs ឥណ្ឌូនេស៊ី នៅកោះបាលី ដែលមានអ្នកចូលរួមមានចំនួន ៩៨រូប មកពីប្រទេស កម្ពុជា ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ វៀតណាម ហ្វីលីពីន ភូមា និង UN NGOs ពិភាក្សាលើបញ្ហាដែលកើតឡើងជុំវិញការរំលោភបំពានពលកម្ម និងជួញដូរមនុស្សលើវិស័យនេសាទ។

### ខ.២ កិច្ចប្រជុំ ជាអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស

➢ កិច្ចប្រជុំក្នុងប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)
  - លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង៖
    - ពិនិត្យសម្រេចលើផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល០៥ឆ្នាំ ២០១៩-២០២៣ អ្នកចូលរួមចំនួន ៧១នាក់ (ស្រី ១៨នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។
    - ស្តីពីការប្រតិបត្តិនីតិវិធីតាមស្តង់ដាប្រតិបត្តិ កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលព្រះរាជាណាចក្រថៃ លើកទី៤។

### ខ.៣. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ២០លើក មានអ្នកចូលរួមសរុប ២១៩នាក់ (ស្រី ១២៨នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ០៨លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ១២លើក។ (**ឧបសម្ព័ន្ធ១**)

## III. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជាៈ

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។

- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## IV. ទិសដៅខែតុលា ឆ្នាំ ២០១៩

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.................ខែ...........ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ...........ឆ្នាំ២០១៩

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ ( សរុបចំនួន ២០លើក ) មនុស្សចំនួន ២១៩នាក់ ( ស្រី ១២៨នាក់ )

| **ស្ថាប័ន សម្របសម្រួល** | **សកម្មភាព** |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | សម្របសម្រួលចំនួន ០៨លើក អ្នកចូលរួមចំនួន ១១នាក់ (ស្រី ០៧នាក់)<br>▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា ដើម្បីសហការសិក្សាលទ្ធភាព រៀបចំសាងសង់អគារទទួលពលករ-ពលការនីកម្ពុជាបញ្ជូនមកពីប្រទេសថៃ និងរៀបចំយន្តការ និងដំណើរការផ្តល់សេវាចម្រុះជូនពលករនៅច្រកទ្វារអន្តរជាតិដូង អ្នកចូលរួមចំនួន១១នាក់ ស្រី ០២នាក់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- កិច្ចប្រជុំត្រៀមអន្តរក្រសួង និងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីចិន ចំនួន០២លើក ស្តីពីកិច្ចការពារកុងស៊ុល រវាងកម្ពុជា-ចិន នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។<br>- ដឹកនាំកិច្ចប្រជុំបន្តរវាងប្រទេសបញ្ជូនពលករទាំង៣ (កម្ពុជា-ឡាវ-ភូមា)និងកិច្ចការពារពលករទេសន្តប្រវេសន៍៖តួនាទី ប្រទេសបញ្ជូន និងប្រទេសទទួល។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ២៥ច្បាប់ លិខិតចូល ១២ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ០៨ច្បាប់ លិខិតចូល ១៥ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែកក្កដា ឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ខែកក្កដា ឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវិគី។<br>- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>- Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ០៤ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ១៣សកម្មភាព។ |

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>- លោកប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះបានចូលរួម៖<br>○ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការសិក្សាមូលដ្ឋានលើយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅសណ្ឋាគារភ្នំពេញ។<br>○ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីសេចក្តីព្រាងដំបូង នៃគោលការណ៍ណែនាំ ស្តីពីយន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារសាន់វេ។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**<br>- លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន **សិរីលក្ខិណា** បានអញ្ជើញចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយ និងចែករំលែកចំណេះដឹង ជូនដល់សមាជិក សមាជិកាសមាគមអតីតកម្មសិក្សាការីកម្ពុជា-កូរ៉េ (ស.អ.ក.ក) "គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា CAMBODIA Sustainable Development Goal (CSDGs)" នៅសណ្ឋាគារភ្នំពេញ។<br>- លោកប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិស្តីទី បានចូលរួមកិច្ចប្រជុំក្រុមការងារខមមីតកម្ពុជា និងក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃ.គ.ជ.ប.ជ ពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រាំបួនខែ ឆ្នាំ២០១៩ នៅសាលប្រជុំក្រសួងកិច្ចការនារី។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១២លើក អ្នកចូលរួមសរុបចំនួន ២០៨នាក់ (ស្រី ១២១នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រីមាសទី៣ ឆ្នាំ២០១៩ អ្នកចូលរួមចំនួន៦៩នាក់ ស្រី២៨នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន០៨លើក អ្នកចូលរួមចំនួន១៣៩នាក់ ស្រី៩៣នាក់។ |
| **ខេត្តបាត់ដំបង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ៖<br>○ បានរៀបចំកិច្ចប្រជុំបូកសរុបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រីមាសទី៣ ឆ្នាំ២០១៩។<br>○ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីលទ្ធផលការងារទេសន្តរប្រវេសន៍ រយៈពេល២ឆ្នាំ និងផែនការអនុវត្តបន្ត។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួមប្រជុំតុមូល ស្តីពីកិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ នៅសណ្ឋាគារសុខាល័យ ខេត្តសៀមរាប។ |